សន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៤
The 4th Cambodian Water Conference & Exhibition

# មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

លោក ប៉ុក ចន្ទ័

ប្រធាននាយកដ្ឋាន ផែនការនិងគ្រប់គ្រងទិន្នន័យ

អគ្គនាយកដ្ឋានទឹកស្អាត

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍

ថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០២២

# ស្ថានភាព និងភាពចាំបាច់ក្នុងការបង្កើតមូលនិធិ

- អនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG។
- ៤៧% នៃភូមិនៅក្នុងប្រទេសកម្ពុជា មិនទាន់មានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ (PIP, 2020)។
- ត្រូវការទុនវិនិយោគ យ៉ាងហោចណាស់ ១៥០ លានដុល្លារអាមេរិក សម្រាប់វិនិយោគដោយវិស័យឯកជន មិនគិតបញ្ចូលនូវការវិនិយោគរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ (PIP, 2020)។
- ចាំបាច់ត្រូវបង្កើតមូលនិធិ ដើម្បីគៀងគរ ធនធានពីប្រភពស្របច្បាប់ផ្សេងៗ ដើម្បីជំរុញដល់ការវិនិយោគក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត។

iSEA
THE STONE FAMILY FOUNDATION
AGENDA FOR CHANGE
water.org
THE AUSTRALIAN WATER PARTNERSHIP
PPIAF Enabling Infrastructure Investment
CAPRED
WaterAid
unicef for every child
FTB
HTS
TCU

# ការបង្កើតមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

សេចក្តីព្រាង **ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត** បានចែងថា៖

**មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត** ត្រូវបានបង្កើតឡើង ដើម្បីធានាឱ្យមាន ការថែទាំ ការធ្វើឱ្យប្រសើរឡើង និងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព ជាពិសេសនៅក្នុងតំបន់កំពុងអភិវឌ្ឍន៍ និងតំបន់ដាច់ស្រយាល។

**មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត** មានប្រភពថវិកាពី ថវិការដ្ឋ ជំនួយ បរិច្ចាគ វិភាគទានរបស់បុគ្គល ដៃគូអភិវឌ្ឍន៍នានា និងប្រភពស្របច្បាប់ផ្សេងៗ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ **មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត** នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

# ការបង្កើតមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

ក្នុងឆ្នាំ២០២១ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) សហការណ៍ជាមួយកម្មវិធីអភិវឌ្ឍន៍របស់ស្ថានទូតអូស្ត្រាលី ដើម្បីរៀបចំបង្កើត **មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត** នេះឡើង។
ទម្រង់ ឬរចនាសម្ព័ន្ធរបស់ **មូលនិធិ** មាន៣ផ្នែក៖

១. ក្របខណ្ឌមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត
២. នីតិវិធីប្រតិបត្តិការស្តង់ដា
៣. សេចក្តីព្រាងអនុក្រឹត្យ

# ១. ក្របខ័ណ្ឌមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

- កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) បានជ្រើសរើសអ្នកជំនាញដែលមានបទពិសោធន៍ក្នុងការបង្កើតមូលនិធិអភិវឌ្ឍន៍ផ្សេងៗ មកសិក្សាបង្កើត **ក្របខ័ណ្ឌមូលនិធិ**។

3i និងអ្នកជំនាញ បានធ្វើការពិគ្រោះយោបល់ជាមួយ៖

- ប្រតិបត្តិករទឹកស្អាត
- ធនាគារ
- ដៃគូអភិវឌ្ឍន៍នានា
- មូលនិធិផ្សេងៗ
- អង្គភាពរដ្ឋាភិបាលផ្សេងៗ

- តាមរយៈការពិគ្រោះយោបល់ គ្រប់ភាគីពាក់ព័ន្ធឯកភាពពីសារៈសំខាន់នៃការបង្កើតមូលនិធិនេះ។
- MISTI និង(3i) បានជួបពិភាក្សាគ្នាពីវឌ្ឍនភាពនិងតម្រង់ទិសដៅបន្តក្នុងការបង្កើត **ក្របខ័ណ្ឌមូលនិធិ**។
- សេចក្តីព្រាង **ក្របខ័ណ្ឌមូលនិធិ** កំពុងត្រូវបានពិនិត្យដោយក្រុមការងារ (3i) បន្ទាប់មកនឹងដាក់ជូនមកក្រសួង ដើម្បីពិនិត្យ កែសម្រួល និងសម្រេច។

# ១. ក្របខ័ណ្ឌមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត(ត)

- ❑ គោលដៅ
  - បង្កើនវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ទុយោ
  - ទឹកស្អាតមានស្តង់ដា និងសុវត្ថិភាព
  - ថ្លៃមានភាពសមរម្យ និងសមធម៌
  - បរិយាបន្នសង្គម
  - ចីរភាពបរិស្ថាន
  - បង្កើនប្រសិទ្ធភាពលើការវិនិយោគ និងប្រតិបត្តិការ
- ❑ ប្រភេទនៃការគាំទ្រ
  - ការផ្តល់បដិភាគដល់ការវិនិយោគ
  - កម្ចីមានភាពអនុគ្រោះ
  - ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព
  - ការឧបត្ថម្ភធនថ្លៃភ្ជាប់នាឡិកាដល់ជនក្រីក្រ
- ❑ តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត
- ❑ ទំហំវិនិយោគដែលវិស័យត្រូវការ
- ❑ ទិសដៅ និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត
- ❑ រចនាសម្ព័ន្ធ និងរដ្ឋបាល

iSEA
The Stone Family Foundation
AGENDA FOR CHANGE
water.org
The Australian Water Partnership
PPIAF Enabling Infrastructure Investment
CAPRED
WaterAid
unicef for every child
FTB
HTS
TCU

# **សកម្មភាពបន្ត**

- បច្ចុប្បន្ន កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) បានបិទបញ្ចប់គម្រោង។

- កម្មវិធីអភិវឌ្ឍន៍ថ្មី របស់ប្រទេសអូស្ត្រាលី ដែលមានឈ្មោះថា **ភាពជាដៃគូកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍប្រកបដោយភាពធន់** (CAP-RED) នឹងបន្តកិច្ចសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ (MISTI) ក្នុងការបង្កើតមូលនិធិ និងបន្តអនុវត្តការងារ២ ដែលនៅសល់ ក្នុងពេលជំណាលគ្នាគឺ៖

១. ការបង្កើត នីតិវិធីប្រតិបត្តិការស្តង់ដា។
២. សេចក្តីព្រាងអនុក្រឹត្យស្តីពីបង្កើត**មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត**។

# សូមអរគុណ!